# ព្រះរាជក្រម

នស/រកម/១១០៥/០៣៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវ ការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម

មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងសម័យប្រជុំលើកទី ៤ តាមសេចក្តីសម្រេចលេខ ៥៤/១០៩ ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ នៅទីក្រុងញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ជសរ.០៥១១.៥០៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ហត្ថលេខា ព្រះហស្តលេខា

ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ ៖ ៤៣៦ - ច.ល

ដើម្បីចម្លងចែកចាយ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោល នូវការផ្តល់ហិរញ្ញប្បទាន ដល់អំពើភេរវកម្ម

អង្គការសហប្រជាជាតិ

១៩៩៩

# អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម

## បុព្វកថា

រដ្ឋសមាជិកទាំងអស់នៃអនុសញ្ញានេះ

*ដោយចងចាំនៅក្នុងចិត្ត* នូវគោលបំណង និង គោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ ទាក់ទងទៅនឹងការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ព្រមទាំងការលើកកំពស់ទំនាក់ទំនងជិតខាងល្អ ក៏ដូចជាចំណងមិត្តភាព និងសហប្រតិបត្តិការរវាងរដ្ឋទាំងឡាយ

*ដោយមានក្តីបារម្ភយ៉ាងជ្រៅជ្រះ* អំពីការរីករាលដាលនៅទូទាំងពិភពលោក នូវអំពើភេរវកម្ម តាមគ្រប់ទម្រង់ និងរូបភាព

*ដោយរំលឹកទៅដល់* សេចក្តីប្រកាសនាឱកាសខួបលើកទីហាសិបនៃអង្គការសហប្រជាជាតិ ដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥០/៦ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៥

*ដោយរំលឹកផងដែរ* ទៅដល់សេចក្តីសម្រេចរបស់មហាសន្និបាត ដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ រួមមានសេចក្តីសម្រេចលេខ ៤៩/៦០ ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៩៤ ព្រមទាំងឧបសម្ព័ន្ធរបស់វា ស្តីអំពីការប្រកាសវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មអន្តរជាតិ ដែលនៅក្នុងនោះ រដ្ឋសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ បានអះអាងជាឱឡារិកនូវការដាក់ទណ្ឌវាទយ៉ាងច្បាស់លាស់ ទៅលើរាល់ទង្វើ វិធីសាស្ត្រ និង ការប្រតិបត្តិនូវអំពើភេរវកម្ម ថាជាអំពើឧក្រិដ្ឋកម្ម និងមិនអាចអត់ឱនឱ្យបាន ទោះជាអំពើនោះត្រូវបានប្រព្រឹត្តនៅទីណា ដោយនរណាក៏ដោយ ហើយរួមបញ្ចូលទាំងអំពើទាំងពួងដែលធ្វើឱ្យអន្តរាយទៅដល់ចំណងមិត្តភាពរវាងរដ្ឋទាំងឡាយ និងប្រជាជនទាំងឡាយ និងដែលគំរាមកំហែងទៅដល់បូរណភាពទឹកដី ព្រមទាំងសន្តិសុខរបស់រដ្ឋនានា

*ដោយកត់សំគាល់ឃើញថា* សេចក្តីប្រកាសស្តីអំពីវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មអន្តរជាតិ ក៏បានលើកទឹកចិត្តផងដែរ ឱ្យរដ្ឋទាំងឡាយធ្វើការពិនិត្យឡើងវិញជាបន្ទាន់ នូវវិសាលភាពនៃបទបញ្ញត្តិច្បាប់អន្តរជាតិដែលមានស្រាប់ ស្តីអំពីការបង្ការ ការបង្ក្រាប និងការលុបបំបាត់ចោល នូវអំពីភេរវកម្មគ្រប់ទម្រង់ និងគ្រប់រូបភាព ក្នុងគោលបំណងធ្វើការធានាឱ្យបានថា មានក្របខ័ណ្ឌច្បាប់យ៉ាងទូលំទូលាយ សម្រាប់គ្រប់គ្រងទៅលើរាល់ទិដ្ឋភាពនៃបញ្ហានេះ

*ដោយរំលឹកទៅដល់* កថាខ័ណ្ឌទី៣ វាក្យខ័ណ្ឌ(ច) នៃសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥១/២១០ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលនៅក្នុងនោះ មហាសន្និបាតបានអំពាវនាវដល់រដ្ឋទាំងអស់ ឱ្យធ្វើការបង្ការ និងរារាំង តាមរយៈវិធានការក្នុងស្រុកសមស្រប ចំពោះការផ្តល់ហិរញ្ញប្បទានទៅដល់ភេរវករ និងអង្គការភេរវកម្មនានា ទោះបីជាការផ្តល់ហិរញ្ញប្បទាននោះ ធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលតាមរយៈអង្គការនានា ដែលមាន ឬអះអាងថាមានគោលដៅ

សប្បុរសធម៌ សង្គម ឬវប្បធម៌ ឬដែលធ្វើសកម្មភាពខុសច្បាប់ ដូចជាការជួញដូរអាវុធខុសច្បាប់ ការរកស៊ីខាងគ្រឿងញៀន និងបទទុច្ចរិតផ្សេងទៀត រួមមានការធ្វើអាជីវកម្មលើមនុស្សក្នុងគោលបំណងផ្តល់ហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម និងជាពិសេសឱ្យធ្វើការពិចារណា ក្នុងករណីដែលសមស្រប អំពីការបង្កើតវិធានការនិយ័តកម្ម ដើម្បីបង្ការ និងរារាំងការធ្វើចរាចរណ៍នៃមូលនិធិដែលត្រូវបានសង្ស័យថាមានគោលដៅបំរើឱ្យសកម្មភាពភេរវកម្ម ដោយធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ ទៅដល់សេរីភាពនៃការធ្វើចរាចរណ៍មូលធនស្របច្បាប់ និងឱ្យពង្រឹងការផ្លាស់ប្តូរពត៌មានដែលទាក់ទងទៅនឹងចរាចរណ៍ជាអន្តរជាតិ នៃមូលនិធិបែបនេះ

*ដោយរំឭកផងដែរ* ទៅដល់សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥២/១៦៥ ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧ ដែលនៅក្នុងនោះ មហាសន្និបាតបានអំពាវនាវដល់រដ្ឋទាំងអស់ ឱ្យធ្វើការពិចារណាជាពិសេសទៅលើការអនុវត្តវិធានការនានា ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៣ (ក) ដល់ (ច) នៃសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥២/២១០ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦

*ដោយរំឭកបន្តទៀត* ទៅដល់សេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥៣/១០៨ ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ១៩៩៨ ដែលនៅក្នុងនោះ មហាសន្និបាតបានសម្រេចថា គណៈកម្មាធិការអាដហុក ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥១/២១០ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦ គួរតែធ្វើការតាក់តែងសេចក្តីព្រាងនៃអនុសញ្ញាអន្តរជាតិមួយ ស្តីអំពីការលុបបំបាត់ចោល នូវការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដើម្បីបំពេញបន្ថែមទៅលើលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធដែលមានស្រាប់

*ដោយយល់ឃើញថា* ការផ្តល់ហិរញ្ញប្បទានទៅដល់អំពើភេរវកម្ម គឺជាបញ្ហាមួយដែលបង្កក្តីបារម្ភយ៉ាងធ្ងន់ធ្ងរចំពោះសហគមន៍អន្តរជាតិទាំងមូល

*ដោយកត់សំគាល់ឃើញថា* ចំនួន និងភាពធ្ងន់ធ្ងរនៃអំពើភេរវកម្មអន្តរជាតិ អាស្រ័យទៅលើហិរញ្ញប្បទានដែលភេរវករអាចនឹងទទួលបាន

*ដោយកត់សំគាល់ឃើញផងដែរថា* លិខិតូបករណ៍គតិយុត្តិពហុភាគីដែលមានស្រាប់ ពុំបានកំណត់ឱ្យបានច្បាស់លាស់អំពីការផ្តល់ហិរញ្ញប្បទានបែបនេះ

*ដោយយល់* អំពីតម្រូវការបន្ទាន់ដើម្បីលើកកំពស់សហប្រតិបត្តិអន្តរជាតិ រវាងរដ្ឋទាំងឡាយ ក្នុងការបង្កើត និងអនុម័តវិធានការប្រកបដោយប្រសិទ្ធិភាព សម្រាប់ការបង្ការការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ក៏ដូចជាសម្រាប់ការលុបបំបាត់ទង្វើទាំងនោះ តាមរយៈការចោទប្រកាន់ និងការដាក់ទណ្ឌកម្មទៅលើអ្នកប្រព្រឹត្ត